00346140

E90

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 03 / JULY / 2009
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. Ty

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧-អវតក/អជសដ
**Case File/Dossier No. 001/18-07-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម **យ៉ា សុខន**
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **ធូ មណី**

កាលបរិច្ឆេទ: ថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ២០០៩
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 03 / JULY / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. Ty

# សេចក្ដីសម្រេចលើសំណើរបស់ អៀង សារី សុំដាក់អំណះអំណាងឆ្លើយតបទៅនឹងសំណើ របស់សហព្រះរាជអាជ្ញាស្នើសុំឲ្យអនុវត្តសហឧក្រិដ្ឋកម្មរួម

**សហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**
គង់ ពិសី
ហុង គីមសួន
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE

ទី ស្រីនណា
Pierre Olivier SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE
Elizabeth RABESANDRATANA
Karim KHAN

**ជនជាប់ចោទ**
កាំង ហ្គេកអ៊ាវ ហៅ ឌុច

**មេធាវីជនជាប់ចោទ**
ការ សាវុត្ថ
François ROUX
Marie-Paule CANIZARES

**មេធាវីលោក អៀង សារី**
អាង ឧត្ដម
Michael G. KARNAVAS

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អវតក”)

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសង អនុលោម “តាមសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី កាំង ហ្កេកអ៊ាវ ហៅ ឌុច” ដែលអង្គបុរេជំនុំជម្រះបានសម្រេច និងប្រកាសនៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ និងបញ្ចូលសេចក្តីសម្រេចនេះជាភាសាខ្មែរទៅក្នុងសំណុំរឿងនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៨(“សេចក្តីសម្រេច”)។

**ក្រោយពីបានទទួល** “សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម” ដែលដាក់ដោយសហព្រះរាជអាជ្ញានៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៩ (“សំណើសុំរបស់សហព្រះរាជអាជ្ញា”)[1]។

**ក្រោយពីបានទទួល** “សំណើជាបន្ទាន់របស់លោក អៀង សារី សុំដាក់អំណះអំណាងឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឱ្យអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម លើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ “ឌុច” ដែលដាក់ដោយសហមេធាវីការពារក្តីលោក អៀង សារី ដែលជាជនត្រូវចោទនៅក្នុងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស ដែលបច្ចុប្បន្នសំណុំរឿងនេះនៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (“សំណើសុំរបស់ អៀង សារី”)[2]។

---

1 “សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម” ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៩ (ឯកសារលេខ E73)។

2 “សំណើជាបន្ទាន់របស់លោក អៀង សារី សុំដាក់អំណះអំណាងឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឱ្យអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម លើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ “ឌុច” ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩។

## ចេញសេចក្តីសម្រេចដូចខាងក្រោមនេះ ÷

### ក. សេចក្តីផ្តើម

១. នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាបានដាក់សំណើសុំឱ្យអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម ("JCE") ជាទម្រង់ទទួលខុសត្រូវនៅក្នុងសំណុំរឿង០០១ ចំពោះបទល្មើសនានាដែលបានប្រព្រឹត្តដោយជនជាប់ចោទ កាំង ហ្គេកអ៊ាវ តែនៅមន្ទីរសន្តិសុខស-២១ ប៉ុណ្ណោះ។

### ខ. សារណា

២. អៀង សារី ដែលជាជនត្រូវចោទនៅក្នុងសំណុំរឿងលេខ០០២ ស្នើសុំការអនុញ្ញាតដើម្បីឱ្យខ្លួនអាចដាក់អំណះអំណាងជាលាយលក្ខណ៍អក្សរចំពោះមុខអង្គជំនុំជម្រះសាលាដំបូងឆ្លើយតបទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញា[3]។ មេធាវីការពារក្តីលោក អៀង សារី តវ៉ាថា ការអនុវត្តសហកម្មឧក្រិដ្ឋកម្មនៅអ.វ.ត.ក បានប៉ះពាល់យ៉ាងខ្លាំងដល់លោក អៀង សារី ពីព្រោះគាត់ត្រូវបានគេចោទប្រកាន់ថាបានចូលរួមក្នុង "ផែនការឧក្រិដ្ឋរួម" ជាមួយនឹងលោក កាំង ហ្គេកអ៊ាវ ហើយទោះបីជាមានការបំបែកសំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសង និងសំណុំរឿង០០២/១៩-០៩-២០០៧-អវតក/អជសង ជាផ្លូវការក៏ដោយ ប៉ុន្តែរឿងក្តីទាំងពីរនេះមានទំនាក់ទំនងគ្នាទៅវិញទៅមកយ៉ាងខ្លាំង ហើយលោក អៀង សារី មានចំណាប់អារម្មណ៍យ៉ាងច្បាស់ចំពោះលទ្ធផលនៃសំណើសុំរបស់សហព្រះរាជអាជ្ញា។

### គ. ការប្រជុំពិភាក្សាសម្រេច

៣. លោក អៀង សារី មិនមែនជាភាគីក្នុងសំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសង ហេតុដូច្នេះគាត់មិនមានសិទ្ធិស្របច្បាប់ណាមួយក្នុងការដាក់សំណើ និងអំណះអំណាង

---

[3] សារណាជាលាយលក្ខណ៍អក្សរត្រូវបានភ្ជាប់នឹងសំណើរបស់លោក អៀង សារី ជាឧបសម្ព័ន្ធ ក និង ខ រៀងៗខ្លួន។ សារណាទាំងនេះបានដាក់ពីមុនដោយមេធាវីការពារក្តីលោក អៀង សារី ក្នុងសំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/អជសង ("សារណាជាលាយលក្ខណ៍អក្សរ")។

ជាលាយលក្ខណ៍អក្សរដែលដាក់ភ្ជាប់នឹងសេចក្ដីសម្រេចនេះ[4]។ ទន្ទឹមករណីដែលលើកឡើងដោយមេធាវីការពារក្ដីទាក់ទងនឹងចំណាប់អារម្មណ៍ផ្លូវច្បាប់របស់ពួកគាត់នៅក្នុងលទ្ធផលនៃសំណើសុំរបស់សហព្រះរាជអាជ្ញាមិនមានលក្ខណៈគ្រប់គ្រាន់សម្រាប់ឱ្យអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឱ្យពួកគាត់ដាក់អំណះអំណាងនៅក្នុងរឿងក្ដីនេះទេ។

៤. ម្យ៉ាងវិញទៀត មេធាវីការពារក្ដីលោក អៀង សារី បានលើកអំណះអំណាងថា ការបដិសេធសំណើរបស់ខ្លួននឹងរំលោភបំពានលើសិទ្ធិទទួលបានសមភាពនៃកម្លាំងក្នុងដំណើរការនីតិវិធី[5]។ សមភាពនៃកម្លាំង គឺជាគោលការណ៍ច្បាប់ដែលសហមេធាវីការពារក្ដី និងសហព្រះរាជអាជ្ញាត្រូវមានសមភាពក្នុងកិច្ចនីតិវិធីដើម្បីធានាថា ការអនុវត្តកិច្ចដំណើរការនីតិវិធីតុលាការមានភាពយុត្តិធម៌[6]។ ប៉ុន្តែ ទោះបីជាលក្ខណៈជាមូលដ្ឋាននៃគោលការណ៍នេះ ត្រូវបានទទួលស្គាល់នៅក្នុងវិធានផ្ទៃក្នុង និងដោយអង្គជំនុំជម្រះក៏ដោយ គោលការណ៍នេះត្រូវបានយកមកអនុវត្តតែចំពោះភាគីនៅក្នុងរឿងក្ដីតែមួយប៉ុណ្ណោះ[7]។ គោលការណ៍សមភាពនៃកម្លាំង មិនអាចអនុវត្តចំពោះភាគីនៅក្នុងការជំនុំជម្រះរឿងក្ដីដាច់ដោយឡែកពីគ្នានោះទេ។

## ឃ. សេចក្ដីសម្រេច

**តាមរយៈសំអាងហេតុដែលបានលើកឡើងខាងលើ អង្គជំនុំជម្រះសាលាដំបូង÷**

---

[4] វិធាន៩២ នៃវិធានផ្ទៃក្នុង អនុញ្ញាតភាគីដំណើរការនីតិវិធីឱ្យដាក់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរចំពោះមុខតុលាការ រហូតដល់ការបញ្ចប់នៃការដាក់សេចក្ដីសន្និដ្ឋាន។

[5] សំណើសុំរបស់លោក អៀង សារី កថាខណ្ឌ៨-១២។

[6] សូមមើល *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Taylor* សំណុំរឿងលេខ SCSL-03-01-T អង្គជំនុំជម្រះតុលាការកំពូល "សេចក្ដីសម្រេចលើការជូនដំណឹងឧទ្ធរណ៍របស់មេធាវីការពារក្ដី និងសេចក្ដីសន្និដ្ឋាន ទាក់ទងនឹងសេចក្ដីសម្រេចផ្ទាល់មាត់ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៨ តម្រូវឱ្យមេធាវីការពារក្ដីចាប់ផ្ដើមរឿងក្ដីរបស់ខ្លួនថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៨" ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ កថាខណ្ឌ១៦-១៨ និងយុត្តិសាស្ត្រដែលដាក់ស្រង់នៅក្នុងសេចក្ដីសម្រេចនេះ។

[7] សូមមើលយុត្តិសាស្ត្រអន្តរជាតិទាក់ទងនឹងបញ្ហាដែលលើកឡើងដោយមេធាវីលោក អៀង សារី ដែលយុត្តិសាស្ត្រទាំងនេះគាំទ្រដល់សមភាពនៃកម្លាំងដែលបានអនុវត្តរវាងភាគីនៃរឿងក្ដី។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Tadic* សំណុំរឿងលេខ IT-94-A-A សេចក្ដីសម្រេចអង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩, កថាខណ្ឌ ៤៨-៥២ (ដកស្រង់នៅជើងទំព័រលេខ២៤នៃសំណើសុំរបស់អៀង សារី)។

០០១/១៨ កក្កដា ២០០៧/អវតក/អជសង

E90

**បដិសេធ** ការដាក់នូវសំណើសុំ និងអំណះអំណាងជាលាយលក្ខណ៍អក្សរដែលមានភ្ជាប់ទៅនឹងសេចក្ដីសម្រេចនេះ។

**បង្គាប់ឲ្យ** ផ្នែកគ្រប់គ្រងតុលាការជូនដំណឹងអំពីសេចក្ដីសម្រេចនេះ ដល់សហមេធាវីការពារក្ដីលោក អៀង សារី។

ភ្នំពេញ ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៨

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**